**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៦៣៦ សហវ.[illegible]

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង សម្រាប់ការងារជួសជុលដោយក្រាលក្រួសក្រហម និងក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០២ខ្សែ ប្រវែងសរុប ១៩គ.ម ទទឹងខ្នង លើ ០៤ម ,០៥ម និង០៦ម កម្រាស់ ០,១៥ម និង០,២ម ស្ថិតនៅក្នុងខេត្តបាត់ដំបង។

**យោង:** - លិខិតលេខ ១៩២៥ សហវ.អថ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩២៥/១៦ ក.អ.ជ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង ដើម្បីធ្វើការងារជួសជុលខួបដោយក្រាលក្រួសក្រហម និងក្រាលល្បាយថ្មភ្នំផ្លូវចំនួន ០២ខ្សែ ប្រវែងសរុប ១៩គ.ម ទទឹងខ្នងលើ ០៤ម, ០៥ម និង០៦ម កម្រាស់ ០,១៥ម និង០,២ម ស្ថិតនៅក្នុងខេត្តបាត់ដំបង (ផ្លូវភូមិច្រាំងបាក់-ភូមិព្រៃធំ ស្រុកបវេល ប្រវែង ១២គ.ម ទទឹង ៤ម និង៦ម, ផ្លូវឃុំមានជ័យ-សំឡូត ប្រវែង ៧គ.ម ទទឹង ៥ម)ក្នុងតម្លៃសរុបចំនួន ១ ២៦៧ ៥០០ ០០០រៀល (មួយប៊ីលាន ពីររយហុកសិបប្រាំពីរលាន ប្រាំរយពាន់រៀលគត់)ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ជ. ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
រដ្ឋលេខាធិការ

**ជួ និវិត្ត**

**ចម្លងជូន:**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តបាត់ដំបង
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ